សួស្តី នៅក្នុងរូបភាពនេះគឺនិយាយអំពីការដើរផ្សារដើម្បីទិញអាវយឺត ដែលរូបភាពទី ១ យើងឃើញមានបុរសម្នាក់ដែលគាត់មានអាយុប្រហែលជា ១៨ ឆ្នាំ។ គាត់ពាក់អាវស ដៃខ្លី នៅលើអាវរបស់គាត់អត់មានហោប៉ៅសម្រាប់ដាក់លុយទេ។ ដៃទាំងពីររបស់គាត់ជាប់នឹងចង្កេះ អញ្ចឹង ដៃស្តាំនិងដៃឆ្វេងច្រត់ចង្កេះ។ គាត់កំពុងតែគិតចង់ទិញអាវថ្មីមួយនៅថ្ងៃនេះ ប្រហែលជាអាវរបស់គាត់ចាស់ ដូច្នេះគាត់ចង់បានអាវថ្មី គាត់ចង់បានអាវថ្មី។ អញ្ចឹងគាត់ គាត់គិតចង់ទៅផ្សារដើម្បីទិញអាវថ្មីនៅថ្ងៃនេះ។

បន្ទាប់មកទៀតរូបភាពទី ២ រូបភាពទី ២ គាត់ក៏បានដើរមកជួបមិត្តស្រីរបស់គាត់ ដើម្បី ដើម្បីបបួលមិត្តស្រីរបស់គាត់ទៅផ្សារជាមួយគ្នា។ ដោយសារតែស្រីគឺគាត់ចូលចិត្តដើរផ្សារ ដូច្នេះគាត់មានជំនាញខាងរើសខោអាវ ឬក៏គាត់មានជំនាញខាងដើរផ្សារ អញ្ចឹងដោយសារតែបុរសគាត់អត់សូវដើរផ្សារច្រើនទេ អញ្ចឹង ពេលខ្លះគាត់អត់មានជំនាញក្នុងការទិញខោអាវ ឬក៏ជ្រើសរើសខោអាវទេ អញ្ចឹងគាត់ក៏បានមកបបួលមិត្តស្រីរបស់គាត់ដើម្បីទៅជាមួយគ្នា ដោយសារតែមិត្តស្រីរបស់គាត់ អាចជួយគាត់ អាចជ្រើសរើសខោអាវស្អាតបាន។ អញ្ចឹង គាត់ក៏បាន [...] គាត់ក៏បានមកជួបមិត្តស្រីរបស់គាត់ និងបាននិយាយគ្នា គាត់ក៏បានប្រាប់ទៅមិត្តស្រីរបស់គាត់ថាគាត់ចង់ទិញអាវយឺតដៃខ្លីមួយថ្ងៃនេះ។ មិត្តស្រីរបស់គាត់យើងឃើញ មិត្តស្រីរបស់គាត់ មានអាយុ ១៨ ឆ្នាំដូចគាត់ដែរ។ មិត្តស្រីរបស់គាត់ពាក់អាវសដៃខ្លី និងសក់របស់គាត់វែង និងគាត់ចងសក់។ អញ្ចឹងសក់របស់មិត្តស្រីរបស់គាត់ចង ចងទៅក្រោយ និងគាត់ពាក់អាវសដៃខ្លី។ ពួកគាត់ទាំងពីរកំពុងតែជជែកគ្នា និងមិត្តប្រុសរបស់គាត់ និងមិត្តប្រុសរបស់គាត់កំពុងតែប្រាប់គាត់ថាចង់ទិញអាវយឺត ដូច្នេះពួកគាត់ទាំងពីរក៏បាន ក៏បានដើរ ក៏បានដើរចេញទៅខាងក្រៅជាមួយគ្នាដើម្បីស្វែងរកផ្សារ ឬក៏កន្លែងលក់អាវយឺត។

រូបភាពទី ៣ ពួកគាត់ទាំងពីរក៏បានដើរបណ្តើរគ្នានៅតាមផ្លូវ រហូតមកដល់ផ្សារមួយដែលយើងហៅថាផ្សាររាត្រី។ ផ្សាររាត្រីគឺជាផ្សារដែលបើកតែនៅពេលយប់ទេ នៅពេលព្រឹក នៅពេលថ្ងៃ គឺអត់បើកទេ។ ភាគច្រើនគឺបើកចាប់ពីម៉ោង ចាប់ពីម៉ោង ៤ រហូតទៅដល់យប់ អញ្ចឹងដែលយើងហៅថាផ្សាររាត្រី។ អញ្ចឹងនៅក្នុងផ្សាររាត្រីនោះ យើងឃើញមានលក់អាវយឺតជាច្រើន និងលក់របស់ជាច្រើនទៀត និងលក់របស់ជាច្រើនទៀត។ អញ្ចឹងយើងឃើញនៅក្នុងរូបភាពទី ៣ នោះ មានអ្នកលក់ចំនួន ២ នាក់ ម្នាក់គឺគាត់ពាក់មួក ឈរនៅខាងក្រោយតូបដែលមានដាក់ ដែលមានដាក់ខោអាវ ដែលមានដាក់ខោអាវ ឬក៏របស់ដែលគាត់លក់នោះ ឬក៏ដាក់របស់លក់នោះនៅលើ នៅលើតុ ដើម្បីបង្ហាញភ្ញៀវ ដើម្បីឲ្យភ្ញៀវឃើញ គាត់ គាត់អាចចូលមកទិញ អញ្ចឹងនៅលើតុនោះ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

យើងមើលទៅដូចជាមានខោអាវ មានខោព្យួរនៅខាងក្រោម មានខោព្យួរនៅខាងក្រោម និងនៅខាងលើមានរបស់ផ្សេងៗទៀតជាច្រើន និងយើងឃើញគាត់មានដាក់ឆត្រ គាត់មានដាក់ឆត្រ អញ្ចឹងគាត់ឈរនៅក្រោមឆត្រ និងមានពាក់មួក និងអ្នកលក់ម្នាក់ទៀត គឺគាត់ឈរដាក់ដៃទាំងពីរនៅខាងមុខ ដើម្បីរង់ចាំស្វាគមន៍ភ្ញៀវ ដើម្បីរង់ចាំស្វាគមន៍ភ្ញៀវ។ អញ្ចឹងយើងឃើញនៅក្បែរគាត់ មានស្នូខោអាវដែលមានព្យួរ មានស្នូខោអាវដែលមានព្យួរអាវយឺតជាច្រើនទៅតាមថ្នាក់នីមួយៗ អញ្ចឹងមានខ្លះព្យួរ មានខ្លះព្យួរនៅខាងក្រោម ខ្លះព្យួរនៅខាងលើ ប្រហែលជានៅខាងក្រោមគឺពណ៌ខុសពីនៅខាងលើ អញ្ចឹងពួកគាត់បែងចែកទំហំ បែងចែកពណ៌ព្យួរទៅតាម ទៅតាមថ្នាក់ៗរបស់អាវយឺតនោះ អញ្ចឹងផ្សាររាត្រីដែលយើងឃើញនោះ យើងឃើញ យើងឃើញលក់នៅតាមចិញ្ចើមថ្នល់ និងផ្សាររាត្រីភាគច្រើនគឺលក់នៅពេលយប់ ដែលយើងឃើញមានព្រះខែ យើងឃើញមានព្រះខែមួយចំណិតរះនៅលើមេឃដែលចែងចាំងពន្លឺយ៉ាងស្រស់ស្អាត អញ្ចឹងធ្វើឲ្យអមជាមួយនឹងផ្សាររាត្រីដែលមានមនុស្សគាត់មកដើរផ្សារច្រើនផង អញ្ចឹងធ្វើឲ្យទិដ្ឋភាពនៅក្នុងផ្សាររាត្រីនោះមើលទៅកាន់តែអ៊ូអរ។ អញ្ចឹងពួកគាត់ទាំងពីរ ពួកគាត់ទាំងពីរក៏បានដើរកាត់តូបមួយដែលមានលក់របស់ជាច្រើន ដែលមានលក់ដូចជាខោ មានលក់ដូចជាអាវយឺត និងរបស់ផ្សេងៗទៀត អញ្ចឹងពួកគាត់ទាំងពីរក៏សម្រេចចូលទៅមើលនៅតូបនោះដើម្បីរកអាវយឺត។

បន្ទាប់មកទៀតរូបភាពទី ៤ រូបភាពទី ៤ បុរសដែលគាត់ឈរដាក់ដៃនៅខាងមុខ ដែលរង់ចាំស្វាគមន៍ភ្ញៀវ នៅពេលដែលបុរសនោះដើរចូលមកខាងក្នុង គាត់ក៏បានព្យាយាមណែនាំនូវផលិតផល ឬក៏អាវយឺតដែលគាត់លក់ គាត់ណែនាំអំពីគុណភាព ឬក៏គុណភាព ឬក៏តម្លៃ តម្លៃថោក។ អញ្ចឹងដើម្បីឲ្យបុរសម្នាក់នោះ គាត់អាច បុរសម្នាក់នោះ គាត់សម្រេចចិត្តទិញអាវនៅហាងរបស់គាត់។ អញ្ចឹងជាទូទៅអ្នកលក់ គាត់ត្រូវការនិយាយ ត្រូវការនិយាយប្រាប់អំពីផលិតផលរបស់គាត់ អំពីគុណភាព ឬក៏តម្លៃ ដើម្បីទាក់ទាញភ្ញៀវឲ្យទិញនៅហាងរបស់គាត់។ អញ្ចឹងយើងឃើញអ្នកលក់នោះ គាត់កំពុងតែព្យាយាមបង្ហាញអាវយឺតមួយដែលដាក់នៅជួរខាងក្រោម តែអាវយឺតនោះ យើងឃើញមានពណ៌ស អញ្ចឹងគាត់កំពុងតែបង្ហាញអាវយឺតពណ៌ តែអាវយឺតនោះ យើងឃើញមានពណ៌ មានពណ៌ខៀវ មានពណ៌ខៀវ មានពណ៌ស និងមានពណ៌ជាច្រើនទៀត។ ប៉ុន្តែអ្នកលក់បានណែនាំទៅកាន់បុរសម្នាក់នោះ ពណ៌ខៀវដំបូងគេ ពណ៌ខៀវដំបូងគេ អញ្ចឹងបុរសម្នាក់គាត់ក៏ពេញចិត្តអាវខៀវដែលអ្នកលក់ណែនាំដែរ។ អញ្ចឹងក្រោយពេលដែលបុរសម្នាក់នោះ គាត់ប្រាប់ទៅអ្នកលក់ [...] អ្នកលក់ក៏បានយកអាវខៀវ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ឬក៏បង្ហាញអាវខៀវនោះ ទៅកាន់បុរសម្នាក់នោះ។ អញ្ចឹងបុរសម្នាក់នោះក៏គាត់ពេញចិត្តនូវអាវខៀវ ដែលអ្នកលក់បង្ហាញនោះផងដែរ។

បន្ទាប់មកទៀតរូបភាពទី ៥ រូបភាពទី ៥ គាត់ក៏បានយកអាវនោះចេញពីកន្លែងព្យួរ គាត់យកអាវនោះចេញពីកន្លែងព្យួរ ដើម្បីយកមកមើលឲ្យច្បាស់ ថាតើអាវនោះមានទំហំប៉ុនខ្លួនគាត់ ឬក៏មានរហែកនៅត្រង់ណាដែរ ដែរឬទេ។ អញ្ចឹងអាវថ្មីខ្លះក៏មាន អាវថ្មីខ្លះក៏មានរហែក ឬក៏មានប្រឡាក់នៅផ្នែកណាមួយដែរ។ ដោយសារតែផ្សាររាត្រីគឺយើងលក់នៅតាមផ្លូវ និងយើងព្យួរខោអាវដោយមិន ដោយមិនបានដាក់ថង់ប្លាស្ទិកគ្រប ដូច្នេះ ពេលខ្លះអាចធ្វើខោអាវដែលយើងព្យួរនោះប្រឡាក់ដី។ អញ្ចឹង អញ្ចឹងគាត់ត្រូវ នៅពេល អញ្ចឹង នៅពេលដែលគាត់យកខោអាវចេញពីស្នួនោះ អញ្ចឹងគាត់ត្រូវពិនិត្យមើលអាវនោះជាមុនសិន ថាតើអាវនោះធំ ឬតូច ឬក៏អាវនោះមានប្រឡាក់ ឬក៏រហែកត្រង់ណាដែលទេ។

បន្ទាប់មករូបភាពទី រូបភាពទី ៦ គាត់ក៏បានដោះអាវនោះចេញពីទំពួកខោអាវ អញ្ចឹងគាត់បានដោះអាវនោះចេញពីទំពួកខោអាវ បន្ទាប់មកគាត់ក៏បានដោះអាវរបស់គាត់ចេញ ដើម្បីលអាវថ្មីនោះ ដើម្បីឲ្យដឹងថាអាវថ្មីនោះសមនឹងខ្លួនគាត់ដែរឬទេ? អញ្ចឹងពេលខ្លះនៅពេលដែលយើងមើលនៅខាងក្រៅ យើងមើលទៅឃើញស្អាត និងទំហំប្រហែលជាប៉ុនខ្លួនរបស់យើង ប៉ុន្តែនៅពេលដែលយើងលដាក់នៅខ្លួនរបស់យើង ពេលខ្លះអាវនោះអាចធំជាងយើង អាចតូចជាងយើង ឬក៏ពាក់នៅលើខ្លួនរបស់យើងគឺអត់ស្អាត។ អញ្ចឹងគាត់ត្រូវការលមុនពេលនឹងទិញ អញ្ចឹងបុរសម្នាក់នោះគាត់ដោះអាវខាងក្រៅរបស់គាត់ ដែលអាវខាងក្រៅរបស់គាត់ពាក់អាវសដៃខ្លី គាត់ដោះចេញ និងគាត់ពាក់អាវ និងគាត់ពាក់អាវខៀវចូលមកខាង និងគាត់ពាក់អាវខៀវចូល ចូលមកលើខ្លួនរបស់គាត់ ដើម្បីចង់ដឹងថាអាវរបស់គាត់ល្មមដែរឬទេ។ អញ្ចឹងគាត់ព្យាយាមស៊កដៃម្ខាងចូលហើយ បន្ទាប់មកគាត់ស៊កដៃម្ខាងទៀត បន្ទាប់មកគាត់ស៊កដៃម្ខាងទៀត ដើម្បីឲ្យដឹងថាអាវនោះល្មមខ្លួនគាត់ដែរឬទេ។

អញ្ចឹងបន្ទាប់មកទៀតរូបភាពទី រូបភាពទី ៧ បន្ទាប់ពីបុរសម្នាក់នោះ គាត់បានលអាវពណ៌ខៀវដៃខ្លីនោះចូលទៅក្នុងខ្លួនរបស់គាត់ហើយ គាត់ក៏បាន គាត់ក៏បានមើលឆ្វេងស្តាំ ដើម្បីចង់ដឹងថាអាវរបស់គាត់នោះល្មមនឹងគាត់ដែរឬទេ។ ប៉ុន្តែដោយសារតែពិបាកមើលពេក គាត់ក៏បានសួរអ្នកលក់មានកញ្ចក់ មានកញ្ចក់ទេ ដូច្នេះប្រសិនបើមានគាត់អាចងាយស្រួលមើលឆ្វេង មើលស្តាំ និងមើលខាងក្រោយ។ ប៉ុន្តែជាទូទៅនៅកន្លែងដែលលក់ខោអាវតែងតែមានកញ្ចក់

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ពីព្រោះភ្ញៀវភាគច្រើននៅពេលដែលមកទិញខោអាវ
នៅពេលដែលមកទិញខោអាវតែងតែចង់លខោអាវនៅលើដងខ្លួន
ដើម្បីចង់ដឹងថាខោអាវនោះល្មមនឹងខ្លួនដែរឬទេ។
អញ្ចឹងជាទូទៅអ្នកលក់ត្រូវតែមានកញ្ចក់សម្រាប់ភ្ញៀវ។ អញ្ចឹងជាក់ស្ដែងនៅក្នុងរូបភាពទី ៧ នេះ
អ្នកលក់គាត់មានកញ្ចក់សម្រាប់ជូនភ្ញៀវនៅពេលដែលភ្ញៀវលខោអាវ។
អញ្ចឹងយើងឃើញអ្នកលក់កាន់កញ្ចក់នៅក្នុងដៃ
និងដៃម្ខាងទៀតគាត់ព្យាយាមបង្ហាញទៅបុរសម្នាក់នោះ គាត់អាចមើលកញ្ចក់នោះបាន។
អញ្ចឹងបុរសម្នាក់នោះក្រោយពេលឃើញកញ្ចក់ គាត់ក៏ស្លឹងមើលកញ្ចក់នោះ ងាកមើលឆ្វេង មើលស្ដាំ
ដើម្បីអាចដឹងថាអាវរបស់គាត់ល្មមខ្លួនដែរឬអត់។

បន្ទាប់មកទៀតរូបភាពទី ៨ រូបភាពទី ៨ អ្នកលក់ក៏បានទម្លាក់កញ្ចក់នោះដើម្បីមកក្រោមបន្ទិច
ទម្លាក់កញ្ចក់នោះមកក្រោមបន្តិច ដោយសារតែកញ្ចក់នោះ
យើងឃើញមានចងជាប់នឹងខ្សែប្រហែលជាកញ្ចក់នោះដាក់នៅខ្ពស់ និងចងជាប់ខ្សែ
កុំឲ្យនៅពេលដែលធ្លាក់វាបែក។ អញ្ចឹងគាត់ត្រូវចងជាប់នឹងខ្សែ
នៅពេលដែលព្យួរកញ្ចក់នោះជាប់នឹងជញ្ជាំង អញ្ចឹងគាត់បានទាញខ្សែនោះឲ្យវែងបន្តិច
ដើម្បីទម្លាក់កញ្ចក់នោះឲ្យ ឲ្យចុះមកក្រោមបន្តិច ដើម្បីងាយស្រួលសម្រាប់បុរសនោះ
គាត់អាចមើលខ្លួនរបស់គាត់
គាត់អាចមើលអាវដែលពាក់នៅលើខ្លួនរបស់គាត់បានយ៉ាងងាយស្រួល។ អញ្ចឹងយើងឃើញ
នៅពេលដែលគាត់បានមើលអាវនោះនៅក្នុងកញ្ចក់របស់គាត់
យើងមើលទៅទឹកមុខរបស់គាត់ហាក់បីដូចជាមិនចូលចិត្តអាវនោះទេ ប្រហែលជាពណ៌អាវនោះ
មិនសមទៅនឹងខ្លួនគាត់ ឬក៏អាវនោះមើលទៅដូចជាតូច ឬក៏ធំជាងខ្លួនរបស់គាត់។
អញ្ចឹងមើលទៅគាត់ដូចជាមិនពេញចិត្តនឹងអាវនោះទេ។

អញ្ចឹងបន្តមកទៀតរូបភាពទី ៩ ក្រោយពេលដែលគាត់លហើយ គាត់បានមើលកញ្ចក់ហើយ
គាត់ក៏បានដោះអាវនោះចេញ ដោយគាត់ចាប់ផ្ដើមដោះពីកមុន អញ្ចឹងគាត់ ដោះ បានដោះពី
តាមក្បាលមុន បន្ទាប់មកគឺគាត់ព្យាយាមដោះដៃ ដោះតាមដៃ គាត់ទាញអាវនោះឡើងទៅលើ
ដោះតាមក្បាល។ អញ្ចឹងគាត់ដោះអាវនោះចេញ ដោយសារតែគាត់មិនពេញចិត្តអាវនោះ។

បន្ទាប់មកទៀតរូបភាពទី ១០ រូបភាពទី ១០ ដោយសារតែ
ដោយសារតែអាវដែលគាត់ជ្រើសរើសនោះ គាត់អត់ពេញចិត្ត
បន្ទាប់មកមិត្តស្រីរបស់គាត់ក៏បានជ្រើសរើសអាវឲ្យមិត្តប្រុសរបស់គាត់

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងជាទូទៅស្រីៗគាត់ពូកែខាង ពូកែខាងដើរផ្សារ ពូកែខាងជ្រើសរើសអាវ អញ្ចឹងដោយសារតែ
ដោយសារតែបុរសម្នាក់នោះគាត់រើសអាវនៅពេលដែលដំបូង គាត់រើសហើយ
នៅពេលដែលលដាក់នៅលើដងខ្លួនគាត់អត់ពេញចិត្ត។ អញ្ចឹងមិត្តស្រីរបស់គាត់
ក្រោយពេលដែលឃើញគាត់ អត់ពេញចិត្តនឹងអាវដែលគាត់ជ្រើសរើស
មិត្តស្រីរបស់គាត់ក៏បានរើសអាវយឺតមួយទៀតដែលមានពណ៌ស ដែលមានពណ៌ស
ឲ្យមិត្តប្រុសគាត់។ អញ្ចឹងយើងឃើញអាវយឺតនោះ មានពណ៌សបន្តិច លឿងបន្តិច
មើលទៅបែបជាពណ៌ពងមាន់ ពណ៌ពងមាន់ ពណ៌ពងមាន់មានន័យថាមើលទៅដូចជាសបន្តិចដូចជា
លឿងបន្តិច មិនលឿងខ្លាំង ប៉ុន្តែក៏មិនសដែរ។ អញ្ចឹងមើលទៅ យើងមើលដូចជាពណ៌ពងមាន់
អញ្ចឹងគាត់បានយកអាវនោះឲ្យទៅបុរសម្នាក់នោះ ឲ្យទៅគាត់
មិត្តស្រីរបស់គាត់ក៏បានយកអាវនោះឲ្យទៅមិត្តប្រុសរបស់គាត់ ដើម្បី
ដើម្បីឲ្យមិត្តប្រុសរបស់គាត់លអាវនោះម្តងទៀត។
អញ្ចឹងមិត្តប្រុសរបស់គាត់ក្រោយពេលដែលឃើញមិត្តស្រីយកអាវមួយទៀត យកមកឲ្យ
ធ្វើឲ្យគាត់មានអារម្មណ៍ថា ដូចជាពេញចិត្តនឹងអាវដែលមិត្តស្រីគាត់បានយកមកឲ្យ។

បន្ទាប់មកទៀតរូបភាពទី ១១ បុរសម្នាក់នោះគាត់ក៏បាន បុរសម្នាក់នោះគាត់ក៏បានលអាវនោះ
គាត់ក៏បានពាក់អាវនោះនៅលើដងខ្លួនរបស់គាត់។ បន្ទាប់មកអ្នកលក់ក៏បាន
ក៏បានកាន់កញ្ចក់ដើម្បីឲ្យបុរសម្នាក់នោះគាត់ឆ្លុះមើលខ្លួនរបស់គាត់ ឬក៏អាវនៅលើដង
អាវនៅលើដងខ្លួនរបស់គាត់
ថាតើអាវមួយទៀតដែលមិត្តស្រីរបស់គាត់បានជ្រើសរើសឲ្យសមនឹងខ្លួនគាត់ដែរឬទេ។ អញ្ចឹង
ដោយសារ នៅពេលដែលគាត់បានមើលអាវនោះហើយ
មើលទឹកមុខរបស់គាត់ហាក់បីដូចជាពេញចិត្ត អញ្ចឹងប្រហែលជាអាវនោះគាត់ពេញចិត្តនឹងពណ៌
ដោយសារតែអាវនោះគឺអត់ធំ អត់តូច ប៉ុន្តែល្មមនឹងខ្លួនគាត់។ អញ្ចឹងធ្វើឲ្យគាត់ពេញចិត្ត
និងសប្បាយចិត្តយ៉ាងខ្លាំង និងដោយសារតែអាវនោះគឺជាអាវដែលមិត្តស្រីរបស់គាត់ពេញចិត្ត
និងមិត្តស្រីរបស់គាត់ណែនាំឲ្យផង ដូច្នេះគាត់ពេញចិត្តអាវនោះយ៉ាងខ្លាំង។

រូបភាពទី ១២ ក្រោយពេលដែលគាត់លអាវនោះ និងមើលកញ្ចក់
មើលទៅដូចជាសមនឹងខ្លួនរបស់គាត់ហើយ  គាត់ក៏បានដើរមកខាងក្រៅដើម្បីឲ្យមិត្តស្រីរបស់គាត់
ដើម្បីឲ្យមិត្តស្រីរបស់គាត់ជួយមើល ថាតើអាវដែលពាក់នៅលើខ្លួនរបស់គាត់សមនឹងគាត់ដែរឬទេ។
អញ្ចឹងយើងឃើញអាវដែលមានពណ៌ពងមាន់ ដែលមានពណ៌លឿងបន្តិច ពណ៌សបន្តិចនោះ
ដែលយើងហៅថាពណ៌ពងមាន់ អញ្ចឹងគឺជាអាវយឺតដៃខ្លី
ដូចជាអាវពណ៌ខៀវដែលគាត់លដំបូងដែរ។ អញ្ចឹងក្រោយពេលដែលគាត់លមើលទៅល្មមខ្លួន

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ក្រោយពេលដែលគាត់មើលកញ្ចក់ អញ្ចឹងគាត់ក៏បានដើរចេញមកខាងក្រៅ ដើម្បីបង្ហាញមិត្តស្រីរបស់គាត់ ឬដើម្បីឲ្យមិត្តស្រីរបស់គាត់ជួយមើល ថាតើអាវនោះសមនឹងខ្លួនគាត់ដែរឬទេ។ មិត្តស្រីរបស់គាត់ នៅពេលដែលឃើញមិត្តប្រុសរបស់គាត់លអាវនោះ មិត្តស្រីរបស់គាត់មើលទៅដូចជាពេញចិត្តយ៉ាងខ្លាំង មើលទៅទឹកមុខរបស់គាត់ញញឹម និងដៃទាំងពីររបស់គាត់លើកឡើងហាក់បីដូចជាចង់បង្ហាញពីអារម្មណ៍របស់គាត់ថា អាវនោះពិតជាសមនឹងខ្លួនរបស់មិត្តប្រុសគាត់ណាស់។ និងពណ៌ និងពណ៌របស់អាវនោះក៏ស្អាតដែរ។ អញ្ចឹងពួកគាត់ទាំងពីរពេញចិត្តអាវនោះទាំងអស់គ្នា។

អញ្ចឹងបន្ទាប់មកទៀតរូបភាពទី រូបភាពទី ១៣ ក្រោយពេលដែលបុរសម្នាក់នោះ [គាត់មើល] ក្រោយពេលដែលបុរសម្នាក់នោះគាត់បង្ហាញអាវរបស់គាត់ទៅមិត្តស្រីរបស់គាត់ ដើម្បីឲ្យមិត្តស្រីរបស់គាត់ជួយមើល និងពួកគាត់ទាំងពីរពេញចិត្តអាវនោះហើយ គាត់ក៏បានដោះអាវនោះចេញ គាត់ក៏បានដោះអាវនោះចេញ និងប្រគល់អាវនោះឲ្យទៅអ្នកលក់ ដើម្បីឲ្យអ្នកលក់ជួយខ្ចប់ ដើម្បីឲ្យអ្នកលក់ជួយខ្ចប់ និងដំបូងគាត់ត្រូវសួរតម្លៃអ្នកលក់សិន ប្រសិនបើថ្លៃពេក ក៏គាត់មិនអាច ក៏គាត់អត់ទិញដែរ។ អញ្ចឹងគាត់សួរតម្លៃអ្នកលក់ អញ្ចឹង នៅពេលអ្នកលក់ប្រាប់តម្លៃទៅគាត់ហើយ គាត់ក៏អាចទទួលយកតម្លៃនោះបាន និងគាត់ពេញចិត្តនឹងអាវនោះផង អញ្ចឹងក៏គាត់ឲ្យអ្នកលក់ខ្ចប់ ក៏គាត់ឲ្យអ្នកលក់ខ្ចប់អាវនោះឲ្យគាត់។

អញ្ចឹងរូបភាពទី រូបភាពទី ១៤ រូបភាពទី ១៤ អញ្ចឹងអ្នកលក់ក៏បានយកអាវយឺតពណ៌ពងមាន់ដៃខ្លីនោះយកមកខ្ចប់ អញ្ចឹងអ្នកលក់ត្រូវបត់អាវនោះឲ្យស្អាតជាមុនសិន បន្ទាប់មកដាក់អាវនោះចូលទៅក្នុង ដាក់អាវនោះចូលទៅក្នុងថង់ ចូលទៅក្នុងថង់ដើម្បីឲ្យភ្ញៀវ។ អញ្ចឹងជាទូទៅនៅពេលដែលភ្ញៀវគាត់ទិញខោអាវ អ្នកលក់ត្រូវដកខោអាវនោះចេញពីទំពួកខោអាវ បន្ទាប់មកត្រូវបត់ខោអាវនោះឲ្យស្អាត និងដាក់ខ្ចប់ចូលទៅក្នុងថង់ ដើម្បីហុចទៅឲ្យអ្នកទិញ ដោយសារតែអ្នកទិញគាត់ [...] ដោយសារតែអ្នកទិញគាត់ត្រូវការថង់ដើម្បីយួរ នៅពេលដែលគាត់ទិញអាវយឺតហើយ ដូច្នេះអ្នកលក់ត្រូវតែរៀបចំអាវនោះ ឬក៏បត់អាវនោះឲ្យស្អាត និងដាក់ចូលទៅថង់ ក្នុងថង់ក្រដាស ឬក៏ថង់ប្លាស្ទិកដើម្បីឲ្យទៅអ្នកលក់ ដើម្បីឲ្យទៅអ្នកទិញ ដើម្បីឲ្យអ្នកទិញ ងាយស្រួលយួរត្រលប់ទៅផ្ទះវិញ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកទៀតរូបភាពទី ១៥ រូបភាពទី ១៥ ក្រោយពេលដែលនៅក្នុង រូបភាពទី [១០] ក្រោយពេលដែលនៅក្នុងរូបភាពទី ១៣ គាត់បានសួរតម្លៃ និងគាត់បានហុចអាវនោះឲ្យទៅអ្នកលក់ខ្ចប់ អញ្ចឹងរូបភាពទី ១៥ គាត់ក៏បានប្រគល់លុយឲ្យទៅអ្នកលក់ ដោយតម្លៃអាវយឺតនោះមានតម្លៃមួយម៉ឺនរៀល។ អញ្ចឹងអាវយឺតដែលគាត់ទិញនោះ មានតម្លៃមួយម៉ឺនរៀល។ ជាទូទៅអីវ៉ាន់ អាវ របស់របរដែលលក់នៅផ្សាររាត្រី ជាទូទៅគឺថោក ដោយសារតែនៅផ្សាររាត្រីភាគច្រើនគឺលក់នៅតាមចិញ្ចើមថ្នល់ ឬក៏តាមចិញ្ចើមផ្លូវ។ ដូច្នេះអីវ៉ាន់មួយចំនួនដែលលក់នៅទីនោះ ភាគច្រើនគឺថោក អញ្ចឹងអាវយឺតដែលបុរសដែលទិញ ដែល បុរសនោះគាត់ទិញ និងបានប្រគល់លុយឲ្យទៅអ្នកលក់នៅក្នុងរូបភាពទី ១៥ នោះ គឺអាវនោះមានតម្លៃមួយម៉ឺនរៀល។ អញ្ចឹងបុរសម្នាក់នោះគាត់ក៏បានហុចលុយឲ្យទៅអ្នកលក់មួយម៉ឺនរៀល។ ក្រោយពេលដែលអ្នកលក់បាន បានខ្ចប់ខោអាវនោះដាក់ចូលទៅក្នុងថង់ ឬក៏បានបត់ខោអាវនោះ ដាក់ចូលទៅក្នុងថង់ និងនៅពេលដែលអ្នកលក់ហុចឲ្យគាត់ គាត់ក៏បានប្រគល់លុយ ឬក៏ហុចលុយឲ្យទៅអ្នកលក់វិញ ដោយអាវនោះមានតម្លៃមួយម៉ឺនរៀល។

បន្ទាប់មកនៅក្នុងរូបភាពចុងក្រោយ រូបភាពទី ១៦ រូបភាពទី ១៦ ពួកគាត់ទាំងពីរ ក៏បានដើរត្រលប់ទៅផ្ទះវិញ។ ដោយពួកគាត់ទាំងពីរដើរបណ្ដើរជជែកគ្នាបណ្ដើរ ដោយយើងឃើញរូបភាពនេះមិត្តស្រីរបស់គាត់គឺយើងឃើញពាក់អាវស ដៃខ្លី និងស្លៀកខោវែងពណ៌ខ្មៅ។ អញ្ចឹងពួកគាត់ទាំងពីរពាក់អាវយឺតពណ៌សដៃខ្លីដូចគ្នា។ ប៉ុន្តែស្លៀកខោពណ៌ខុសគ្នា មិត្តស្រីរបស់គាត់ស្លៀកខោជើងវែងពណ៌ខ្មៅ គាត់ស្លៀកខោពណ៌ស ជើងវែង។ អញ្ចឹងគាត់ពាក់អាវពណ៌ និងពណ៌ដូចគ្នា អាវដៃខ្លីដូចគ្នា ប៉ុន្តែខោ ខោជើងវែងដូចគ្នា ប៉ុន្តែពណ៌ខុសគ្នា។ អញ្ចឹងពួកគាត់ដើរបណ្ដើរ ជជែកគ្នាបណ្ដើរ ដោយមើលទឹកមុខរបស់គាត់ហាក់បីដូចជាសប្បាយរីករាយ និងការដើរផ្សារ[រាត្រី] និង [...] ការដើរផ្សារទិញអាវយឺតថ្មីមួយនៅផ្សាររាត្រី [...] ដែលលក់នៅតាមចិញ្ចើមថ្នល់នោះ។ អញ្ចឹងពួកគាត់ដើរត្រលប់ទៅផ្ទះវិញ ដោយយើងឃើញនៅក្នុងដៃខាងឆ្វេងរបស់បុរសម្នាក់នោះ គាត់បានយួរ គាត់បានយួរនូវថង់មួយ ដែលថង់នោះមានដាក់អាវយឺតដែលគាត់ទើបនឹងទិញនៅផ្សាររាត្រីនោះ។ អញ្ចឹងពួកគាត់ដើរបណ្ដើរជជែកគ្នាបណ្ដើរយ៉ាងសប្បាយរីករាយ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.